00715678

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

លេខ៖ -៣១-

**សំណុំរឿងព្រហ្មទណ្ឌលេខ:** ០០២/១៩-០៩-២០០៧-អវតក/ អបជ (០៨)

**ចំពោះមុខ:**
ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន៉ីយ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**កាលបរិច្ឆេទ:** ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១១

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 15 / 07 / 2011
ម៉ោង (Time/Heure) : 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

---

**<u>សាធារណៈ (សំណៅកោសលុប)</u>**

**សេចក្តីសម្រេចលើសំណើរបស់ អៀង សារី សុំឲ្យបង្ហាញឯកសារ អបជ ០៨ ទាំងអស់ មកអង្គភាពគាំពារការការពារក្តី**

---

**<u>សហចៅក្រមស៊ើបអង្កេត</u>**

យូ ប៊ុនឡេង
Siegfried BLUNK

**<u>ជនជាប់ចោទ</u>**

អៀង សារី

**<u>សហព្រះរាជអាជ្ញា</u>**

ជា លាង
Andrew CAYLEY
[redacted]
Dale Lysak

**<u>សហមេធាវីការពារក្តីជនជាប់ចោទ</u>**

អាង ឧត្តម
Michael G. KARNAVAS

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (**"អ.វ.ត.ក"**) បានទទួល "សំណើរបស់ អៀង សារី សុំឱ្យបង្ហាញឯកសារ អបជ ០៨ ទាំងអស់ មកអង្គភាពគាំពារការការពារក្តី" ដែលបានដាក់ដោយសហមេធាវីការពារក្តី អៀង សារី កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១១ ("សំណើ")[១] ។

១. តាមរយៈសំណើសុំរបស់ខ្លួន សហមេធាវីការពារក្តីបានស្នើសុំឱ្យអង្គបុរេជំនុំជម្រះអនុញ្ញាតឱ្យអង្គភាពគាំពារការការពារក្តី ("DSS") អាចចូលមើលឯកសារទាំងអស់ដែលមាននៅក្នុងសំណុំរឿង អបជ ០៨ ដែលបច្ចុប្បន្ននេះ ឯកសារទាំងនេះភាគច្រើនត្រូវបានចាត់ជាប្រភេទឯកសារ "សម្ងាត់ បំផុត"។ សហមេធាវីលើកទឡ្ហីករណ៍ថា សំណើនេះគឺជាការចាំបាច់ ដោយសារតែសេចក្តីសម្រេច ថ្មីៗនេះរបស់អង្គជំនុំជម្រះសាលាដំបូងលើញត្តិរបស់ អៀង សារី សុំឱ្យមានសវនាការដេញដោលទៅលើការបំពេញកិច្ចស៊ើបសួរ ដែលនៅក្នុងសេចក្តីសម្រេចនេះ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធញត្តិនេះ និងបានបញ្ជូន "បញ្ហានេះមកអង្គភាពគាំពារការការពារក្តី ដើម្បីធ្វើការត្រួតពិនិត្យ ហើយដោយផ្អែកតាមសិទ្ធិអំណាចរបស់ខ្លួន អង្គភាពនេះបដិសេធនូវការបង់ប្រាក់សម្រាប់ការងារដែលបានបំពេញ ក្នុងករណីដែលការងារនោះ "មិនចាំបាច់ និងមិនសមស្រប" (មាត្រា ១០ នៃការណែនាំអំពីជំនួយផ្នែកច្បាប់នៅ អ.វ.ត.ក [sic]) និងដោយផ្អែកតាមវិធាន ១១ (២)(ជ) នៃវិធានផ្ទៃក្នុង អង្គភាពនេះទទួលខុសត្រូវក្នុងការត្រួតពិនិត្យ និងវាយតម្លៃលើការបំពេញការងារនៃគ្រប់កិច្ចសន្យាទាំងអស់ [រវាងអង្គភាពនេះជាមួយមេធាវីការពារក្តី] និងអនុញ្ញាតិឱ្យផ្តល់ប្រាក់កម្រៃស្របទៅតាមបទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការការពារក្តី" [២] ។

---

[១] សំណើរបស់ អៀង សារី សុំឱ្យបង្ហាញឯកសារ អបជ ០៨ ទាំងអស់ មកអង្គភាពគាំពារការការពារក្តី ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១១ ឯកសារលេខ ២៩។

[២] សំណើសុំ កថាខណ្ឌ ២ ដែលបានយោងលើសេចក្តីសម្រេចលើញត្តិរបស់ អៀង សារី សុំឱ្យមានសវនាការដេញដោលទៅលើការបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០១១ ឯកសារ E71/1 ("សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង")។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C * C.E.T.C.

២. អ្នកឆ្លើយតបនៅក្នុងរឿងក្ដីនេះ [redacted] មិនបានដាក់ចម្លើយតបណាមួយទៅនឹងសំណើសុំនៅក្នុងរយៈពេលដែលបានកំណត់នៅក្នុងវិធានផ្ទៃក្នុងនោះទេ។

៣. អង្គបុរេជំនុំជម្រះរំឭកថា បន្ទាប់ពីឯកសារទាំងនោះត្រូវបានដាក់មក អង្គបុរេជំនុំជម្រះបានចាត់ឯកសារទាំងឡាយនៅក្នុងសំណុំរឿង អបជ ០៨ ថាជាប្រភេទ "ឯកសារសម្ងាត់បំផុត"។ ដូច្នេះ ឯកសារទាំងនោះនៅតែ "បើកចំហរជូនចំពោះតែចៅក្រម និងបុគ្គលផ្សេងទៀត ដែលរួមមានបុគ្គលិកតុលាការដែលត្រូវការពិនិត្យមើលឯកសារ ដើម្បីបំពេញភារកិច្ចរបស់ខ្លួន ប៉ុន្តែសិទ្ធិមើលឯកសារត្រូវទទួលបានសេចក្ដីសម្រេចពីតុលាការជាមុន" យោងតាមសេចក្ដីណែនាំអនុវត្តស្ដីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងសំណុំរឿង ("សេចក្ដីណែនាំអនុវត្តស្ដីពីចំណាត់ប្រភេទ")[៣]។ ដូច្នេះ បុគ្គលិកអង្គភាពគាំពារការការពារក្ដី មកទល់នឹងពេលនេះ មិនត្រូវបានអនុញ្ញាតឲ្យមើលសំណុំរឿងនេះទេ។

៤. នៅក្នុងសេចក្ដីសម្រេចលើសំណើរបស់ អៀង សារី សុំធ្វើចំណាត់ឯកសារ អបជ ០៨ ទាំងអស់ ឡើងវិញជាឯកសារសាធារណៈ អង្គបុរេជំនុំជម្រះបានសម្រេចថា សំណុំរឿង អបជ ០៨ នៅតែជាឯកសារ"សម្ងាត់បំផុត"ដដែល។ ផ្អែកតាមវិធានស្ដីពីនីតិវិធីនៅកម្រិតអន្តរជាតិ អង្គបុរេជំនុំជម្រះបានបញ្ជាក់អំពីភាពចាំបាច់ក្នុងការការពារកេរ្ដិ៍ឈ្មោះរបស់បុគ្គល ដែលរងការចោទប្រកាន់ថា បានជ្រៀតជ្រែកចូលកិច្ចការរដ្ឋបាលនៅក្នុងសំណុំរឿងនេះ ដែលពុំមានការដាក់ឯកសារសម្រាប់កិច្ចដំណើរការនីតិវិធីតុលាការប្រឆាំងនឹងបុគ្គល ដែលពាក់ព័ន្ធផ្អែកតាមអង្គហេតុដែលថា បន្ទាប់ពីបានបញ្ចប់កិច្ចស៊ើបសួរ ការចោទប្រកាន់ត្រូវបានរកឃើញថាគ្មានមូលដ្ឋានទេ[៤]។

[៣] សេចក្ដីណែនាំអនុវត្តស្ដីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងសំណុំរឿង លេខ ០០៤/២០០៩ ដែលបានអនុម័ត នៅថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ២០០៩ មាត្រា ២(ឃ)(ii) [តាមត្រូវគឺមាត្រា ២(ឃ)(iii)]។

[៤] សេចក្ដីសម្រេចលើសំណើរបស់ អៀង សារី សុំធ្វើចំណាត់ឯកសារ អបជ ០៨ ទាំងអស់ ឡើងវិញជាឯកសារសាធារណៈ ចុះថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារលេខ ៣០ កថាខណ្ឌ ៩ ដល់ ១២។



អង្គបុរេជំនុំជម្រះ * E.C.C.C * C.E.T.C * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

៥. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា សហមេធាវីការពារក្ដីមិនបានធ្វើការពន្យល់ថាតើឯកសារទាំងឡាយនៅក្នុងសំណុំរឿង អបជ ០៨ មានការពាក់ព័ន្ធយ៉ាងដូចម្ដេច ទៅនឹងសេចក្ដីសម្រេចលើបញ្ហា ដែលអង្គជំនុំជម្រះសាលាដំបូងបានបញ្ជូនទៅអង្គភាពគាំពារការការពារក្ដីនោះទេ ហើយសហមេធាវីការពារក្ដីក៏មិនបានតវ៉ាទេថា សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងបានផ្អែកលើឯកសារសម្រាប់កិច្ចដំណើរការនីតិវិធី ដែលបានដាក់នៅចំពោះមុខអង្គបុរេជំនុំជម្រះទេ។ ទោះក្នុងករណីណាក៏ដោយ អង្គជំនុំជម្រះសាលាដំបូង ដែលមិនអាចចូលមើលសំណុំរឿង អបជ ០៨ បានទេនោះ[៥] មិនអាចថាបានធ្វើសេចក្ដីសម្រេច ដោយផ្អែកលើឯកសារដែលមាននៅក្នុងសំណុំរឿងនោះទេ។ លើសពីនេះទៀត អង្គជំនុំជម្រះសាលាដំបូងពុំមានយុត្តាធិការក្នុងការសម្រេចថា ឯកសារសម្រាប់កិច្ចដំណើរការនីតិវិធីដែលបានដាក់នៅចំពោះមុខអង្គបុរេជំនុំជម្រះ មិនមានភាពចាំបាច់ និង/ឬ មិនសមហេតុផលនោះឡើយ។

៦. អង្គបុរេជំនុំជម្រះយល់ឃើញថា ឥឡូវនេះ យើងនៅតែចាំបាច់ត្រូវការពារផលប្រយោជន៍របស់អ្នកឆ្លើយតបនៅក្នុងរឿងក្ដីនេះ ដូចដែលសេចក្ដីសម្រេចកាលពីមុនរបស់អង្គជំនុំជម្រះលើសំណើ ស្រដៀងគ្នានេះសុំឲ្យធ្វើចំណាត់ប្រភេទឯកសារឡើងវិញ បានលើកឡើង និងពន្យល់រួចហើយនោះ។ ដោយសារតែផលប្រយោជន៍របស់អ្នកឆ្លើយតបនៅក្នុងរឿងក្ដីនេះ

---

[៥] សូមមើលឯកសារមួយចំនួនក្នុងនោះមានអនុស្សរណៈ: ពាក់ព័ន្ធនឹងចំណាត់ប្រភេទឯកសារនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងទាក់ទិនទៅនឹងសំណុំរឿង អបជ ០៨ ដែលប្រធានអង្គជំនុំជម្រះសាលាដំបូងបានផ្ញើជូនចៅក្រមអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១១ ឯកសារ E76 និងចម្លើយតបទៅនឹងអនុស្សរណៈនេះ ដែលធ្វើឡើងដោយប្រធានអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១១ ឯកសារ PTC/M/02។ ទោះបីជាយ៉ាងណាក៏ដោយ មានការកត់សម្គាល់ឃើញថា សេចក្ដីសម្រេចលើកទីបួនលើសំណើរបស់ អៀង សារី សុំបំពេញកិច្ចស៊ើបសួរក្រោមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ទៅលើសកម្មភាពរបស់[redacted] នៃការិយាល័យសហព្រះរាជអាជ្ញា ពាក់ព័ន្ធទៅនឹងទំនាក់ទំនងដោយភាគីតែម្ខាងជាមួយសមាសភាពអន្តរជាតិ នៃ ក.ស.ច.ស ចុះថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០១១ ឯកសារលេខ ២៣ ត្រូវបានជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូង ពីព្រោះមានការពិចារណាឃើញថាវាជាការចាំបាច់ ក្នុងការជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងអំពីលទ្ធផលនៃកិច្ចដំណើរការនីតិវិធីទាំងអស់នេះ ដែលបានពិចារណាលើបញ្ហានានាដែលអង្គជំនុំជម្រះសាលាដំបូងបានទទួលនាពេលនោះ។

មានសារៈសំខាន់ជាងផលប្រយោជន៍ដែលបានលើកឡើងដោយសហមេធាវីការពារក្តី នៅពេលនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ឯកសារទាំងឡាយនៅក្នុងសំណុំរឿង អបជ 0៨ នៅតែជាឯកសារសម្ងាត់បំផុតដដែល ហើយមានតែបុគ្គលដែលអង្គបុរេជំនុំជម្រះអនុញ្ញាតឲ្យចូលមើលឯកសារប៉ុណ្ណោះ ទើបអាចចូលមើលបាន។

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆ័ន្ទ៖**

បដិសេធសំណើសុំរបស់សហមេធាវីការពារក្តី។ ៚

**ភ្នំពេញ ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១១**

**ប្រធានអង្គបុរេជំនុំជម្រះ**

អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE * E.C.C.C * C.E.T.C

**ប្រាក់ គឹមសាន**